# ល្បែងនេសាទត្រី

## Fishing Game

### 1 ការណែនាំអំពីលក្ខខណ្ឌនានានៃល្បែងនេសាទត្រី

- ល្បែងនេសាទត្រី ជាល្បែងលេងជាក្រុម ដែលអ្នកលេងមានចំនួនចាប់ពី៣ទៅ៤នាក់ក្នុងមួយក្រុម។
- ក្តារូបភាពតំណាងឲ្យសហគមន៍នេសាទមួយ ឬជីវភាពប្រចាំថ្ងៃរបស់អ្នកនេសាទ។ ដំណើរមួយជុំនៃការលេងល្បែងនេះតំណាងឲ្យការនេសាទពេញមួយឆ្នាំ ដោយក្នុងមួយឆ្នាំបែងចែកជារដូវប្រាំង និងរដូវវស្សា។
- អាស្រ័យតាមពេលវេលាអ្នកសម្របសម្រួលអាចអនុញ្ញាតិឲ្យអ្នកលេងល្បែងអាចបោះគ្រាប់ឡុកឡាក់ចំនួន៥ដង ដើម្បីដំណើរការនៃការលេងល្បែងនេះ។
- អ្នកសម្របសម្រួលអាចធ្វើការណែនាំអំពីរូបភាពខ្លះៗនៃល្បែងនេះទៅកាន់អ្នកចូលរួមដើម្បីងាយស្រួលយល់នៅពេលចាប់ផ្តើមលេង ដូចជាកន្លែងនេសាទរបស់សហគមន៍ Fishing Areaតំបន់ផលស្តុកត្រីសហគមន៍ Community Stock Zone (កន្លែងដែលត្រីលូតលាស់ មុនពេលអ្នកនេសាទអាចប្រមូលផល) តំបន់អភិរក្ស Conservation area តំបន់ព្រៃលិចទឹក Flooded forest area នឹងកាតផ្សេងៗទៀតដែលមាននៅក្នុងល្បែងនេះ។

### 2 ដំណើរការនៃការលេងល្បែងនេសាទត្រី

២.១ មុនពេលលេងល្បែង៖ អ្នកលេងល្បែងនីមួយៗក្នុងក្រុមទទួលបាន

- កាតឧបករណ៍នេសាទប្រភេទ២ ចំនួន១ (A type 2 fishing gear card (Simple net / cost: 40,000 R))
- កាតសហគមន៍ ចំនួន១ (1 community stock zone)
- កាតត្រី១ ចំនួន១គីឡូ (1 fish card equal 1kg)
- កាតលុយ ចំនួន 40,000 រៀល (Card Money 40,000 R )
- ចង្កឹះពិណម្នាក់ ចំនួន១ (1 color stick )

➢ ចាប់ផ្តើមលេង

Game playing

- អ្នកលេងត្រូវចាប់យកកាតនេសាទត្រីចំនួន១ មុនពេលបោះគ្រាប់ឡុកឡាក់
- Each turn begins with a player going fishing by drawing one fish card before rolls the dice
- បន្ទាប់ពីបោះគ្រាប់ឡុកឡាក់ អ្នកលេងត្រូវដាក់ចង្កឹះពណ៌របស់ខ្លួនទៅតាមចំនួនលេខនៃគ្រាប់ឡុកឡាក់ ដែលបានបោះ
- After roll the dice the player  will move color stick follow the number of dice on the board

- ក្រោយពីបោះគ្រាប់ឡុកឡាក់បានមួយជុំ អ្នកលេងមានសិទ្ធក្នុងការសម្រេចចិត្តទិញ ឬមិនទិញកាត(តំបន់សហគមន៍ តំអភិរក្ស និងតំបន់ព្រៃលិចទឹក) អាស្រ័យទៅតាមស្ថានភាពជាក់ស្តែងនៅក្នុងសហគមន៍ដែលគាត់រស់នៅ(ថាតើសហគមន៍របស់គាត់ត្រូវការអ្វី)។
- After one round of roll dice the player have own decide for should be buy some cards of the 3 zones or not ( The three zone are conservation zone, community stock zone and flooding forest area) depend on reality of their community( what is basic need of their community?)

➢ ក្រោយពីការលេងល្បែង

The end of game

- ក្រោយពីការលេងបានបញ្ចប់អ្នកលេងទាំងអស់ត្រូវរាប់ចំនួនកាតដែលនៅសល់ពីការលេង និង រាប់ចំនួនលុយទាំងអស់
- When the game finish playing all the player need to count their money card and all of the three zone cards
- ធ្វើការទូទាត់ចំនួនកាត (តំបន់សហគមន៍ តំអភិរក្ស និងតំបន់ព្រៃលិចទឹក)ទៅជាទឹកប្រាក់ដោយក្នុង(១កាត ស្មើ១០,០០០រៀល) និងធ្វើការគុណជាមួយនឹង ទម្ងន់ត្រីដែលមាននៅក្នុងតំបន់នីមួយៗ។
- All cards of three zone ( The conservation zone, community stock zone and flooding forest area) cash 1 cards= 10000 Riel× weight of fish card in each zone
- ជាចុងក្រោយអ្នកលេងត្រូវធ្វើការបូកសរុបលុយទាំងអស់បញ្ចូលគ្នា(លុយដែលទទួលបានពីការលេងនិង លុយដែលទទួលបានពីកាត (តំបន់ទាំង៣)។
- At the end the player total of their money from sell fish and money get from three zone

## 3 ការឆ្លុះបញ្ចាំងនិងចំណាប់រម្មណ៍នៃការលេងល្បែង

**Reflection of play game (10 minutes)**

ការផ្តល់សំណួរខ្លះៗទៅអ្នកលេង ដើម្បីស្វែងយល់ពីយល់ដឹងរបស់ពួកគេមកលើការលេងល្បែងនេះ។ Propose some question to the player to find their understanding about play these game

- តើអ្នកបានទទួលចំណេះដឹងអ្វីខ្លះពីការលេងល្បែងនេះ?
- What did you learn from this game?
- តើអ្នកចាប់អារម្មណ៍ខ្លាំងត្រង់ចំនុចអ្វីខ្លះនៃល្បែងនេះ?
- What is the most interest from this game?

• អ្នកសម្របសម្រួល ត្រូវធ្វើការបង្ហាញពីគំនិតនិងអត្ថន័យនៃការលេងល្បែងនេសាទត្រីនេះ ដើម្បីផ្តល់ជាគំនិត អត្ថប្រយោជន៍ ក៏ដូចជាចំណេះ ទៅដល់អ្នកដែលបានចូលរួម។
• The facilitator will show some ideas and the meaning of playing Fishing game or Board games to participants for provide their knowledge.